## **យុត្តិធម៌មិនប្រក្រតី** (miscarriage of justice)

យុត្តិធម៌មិនប្រក្រតី ដែលគេស្គាល់ផងដែរថា ជាការកាត់ទោសខុស (wrongful conviction) កើតមានពេលដែលបុគ្គលម្នាក់មិនបានប្រព្រឹត្តបទល្មើស ក៏ប៉ុន្តែបែរជាត្រូវបានកាត់ទោស និងមានពិរុទ្ធភាព។

យុត្តិធម៌មិនប្រក្រតី មិនគ្រាន់តែកើតមានក្នុងនីតិវិធីព្រហ្មទណ្ឌទេ ក៏មានក្នុងដំណើរក្ដីរដ្ឋប្បវេណីផងដែរ។ វាកើតមាន ដោយសារមូលហេតុជាច្រើន ដូចជា ការកំណត់អត្តសញ្ញាណជនល្មើសខុស (eyewitness misidentification) ចម្លើយសារភាពដោយបង្ខំ (forced confession) សក្ខីកម្មក្លែងក្លាយ (perjury) ឬកំហុសរបស់អាជ្ញាធរ ដូចជា ប៉ូលីស ឬចៅក្រម ឬមកពីមេធាវីការពារក្ដី។

**ខ្លឹមសារសង្ខេប៖** យុត្តិធម៌មិនប្រក្រតី ជាមូលហេតុសម្រាប់រដ្ឋ ដើម្បីចូលរួមការពារប្រជាពលរដ្ឋតាមផ្លូវទូត ដែលរងការបំពានដោយរដ្ឋផ្សេង។ ស្រដៀងគ្នានេះដែរ យុត្តិធម៌មិនប្រក្រតី អាចបណ្ដាលមកពីការច្រឡំអង្គហេតុ (error of fact) ដែលតម្រូវឲ្យមានសំណងដល់ភាគីរងគ្រោះ ហើយជាមូលដ្ឋានមួយសម្រាប់ត្រួតពិនិត្យ (judicial review) មើលសាលក្រម ឬសាលដីកាដោយតុលាការជាន់ខ្ពស់។